ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
=======

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ
=======

**មាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន ៣២ នាក់ ពីប្រទេសវៀតណាម**

* * * * * *

ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ សហការជាមួយអាជ្ញាធរវៀតណាម បានរៀបចំមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរចំនួន**៣២នាក់** (ក្នុងនោះកុមារមានចំនួន២៤នាក់) ដែលចូលទៅសុំទាននិងលក់ឆ្នោតខុសច្បាប់នៅក្នុងប្រទេសវៀតណាម ត្រឡប់មកកម្ពុជាវិញ នៅព្រឹកថ្ងៃទី **០៤** ខែ **វិច្ឆិកា** ឆ្នាំ **២០១៦** តាមច្រកទ្វារព្រំដែនអន្តរជាតិបាវិត ហើយបានប្រគល់ជូនមន្ទីរសង្គមកិច្ចខេត្តស្វាយរៀង។

ស្ថានអគ្គកុងស៊ុលបានផ្តល់ព័ត៌មានថា ក្នុងចំណោមពលរដ្ឋទាំង៣២នាក់នោះ គឺ២៦នាក់ ត្រូវបានអាជ្ញាធរវៀតណាមឃាត់ខ្លួន និងប្រមូលផ្តុំនៅមជ្ឈមណ្ឌលសង្គ្រោះសង្គមទីក្រុងហូជីមិញ ហើយធ្លាប់បានគ្រោងធ្វើមាតុភូមិនិវត្តន៍មកកម្ពុជាវិញ កាលពីថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ២០១៦ ប៉ុន្តែត្រូវពន្យារពេលរហូតមកដល់បច្ចុប្បន្ននេះ ដោយសារស្ថាប័នពាក់ព័ន្ធរបស់វៀតណាម ពុំទាន់បានបញ្ចប់នីតិវិធី។ ចំណែកពលរដ្ឋ៦នាក់ទៀត ត្រូវបានអាជ្ញាធរវៀតណាមឃាត់ខ្លួន ក្នុងអំឡុងខែតុលាកន្លងទៅនេះ។

ក្នុងចំណោមពលរដ្ឋខ្មែរទាំង៣២នាក់ គឺ៣០នាក់ មានស្រុកកំណើតនៅខេត្តស្វាយរៀង ១នាក់នៅខេត្តកណ្តាល និង១នាក់ទៀតនៅខេត្តកំពង់ស្ពឺ។

សូមបញ្ជាក់ថា គិតត្រឹមខែតុលា ឆ្នាំ២០១៦នេះ ស្ថានអគ្គកុងស៊ុលកម្ពុជាប្រចាំទីក្រុងហូជីមិញ បានសម្របសម្រួលមាតុភូមិនិវត្តន៍របស់ពលរដ្ឋខ្មែរដែលចូលទៅសុំទាននិងលក់ឆ្នោតខុសច្បាប់ ហើយត្រូវបានអាជ្ញាធរវៀតណាមឃាត់ខ្លួន ចំនួន**១៧៤នាក់** (គិតទាំងលើកនេះផង)៕

ភ្នំពេញ, ថ្ងៃទី ០៤ ខែ វិច្ឆិកា ឆ្នាំ ២០១៦

**ជុំ សុន្ទរី**

**អ្នកនាំពាក្យ**

ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ